ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

រាជរដ្ឋាភិបាលកម្ពុជា
លេខៈ ៤៧ . អនក្រ . បក

# អនុក្រឹត្យ
## ស្តីពី
## ការអនុវត្តន៍ថវិកា មួយភាគដប់ពីរ ជាបណ្ដោះអាសន្ន សំរាប់ការគ្រប់គ្រងឆ្នាំ ២០០៤

- បានឃើញរដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យ នស/រកត/១១៩៨-៧២ ចុះថ្ងៃទី ៣០ ខែ វិច្ឆិកា ឆ្នាំ ១៩៩៨ ស្តីពីការតែងតាំងរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ ០២/នស/៩៤ ចុះថ្ងៃទី ២០ ខែ កក្កដា ឆ្នាំ ១៩៩៤ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការរៀបចំ និង ការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រមលេខ នស/រកម/០១៩៦/១៨ ចុះថ្ងៃទី ២៤ ខែ មករា ឆ្នាំ ១៩៩៦ ដែលប្រកាសឱ្យប្រើច្បាប់ ស្តីពីការបង្កើតក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ
- បានឃើញអនុក្រឹត្យលេខ ០៤ អនក្រ.បក ចុះថ្ងៃទី ២០ ខែ មករា ឆ្នាំ ២០០០ ស្តីពីការរៀបចំ និង ការប្រព្រឹត្តិទៅ នៃក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ
- បានឃើញព្រះរាជក្រមលេខ ០១/នស/៩៣ ចុះថ្ងៃទី ២៨ ខែ ធ្នូ ឆ្នាំ ១៩៩៣ ដែលប្រកាសឱ្យប្រើច្បាប់ស្តីអំពីប្រព័ន្ធហិរញ្ញវត្ថុ ដែលត្រូវបានកែប្រែដោយច្បាប់ ស្តីពីហិរញ្ញវត្ថុ សំរាប់ការគ្រប់គ្រង ឆ្នាំ ១៩៩៥ ដែលប្រកាសឱ្យប្រើដោយព្រះរាជក្រមលេខ ១០ នស ៩៤ ចុះថ្ងៃ ទី ៣១ ខែ ធ្នូ ឆ្នាំ ១៩៩៤ និង ត្រូវបានកែប្រែដោយច្បាប់ ស្តីពីហិរញ្ញវត្ថុ សំរាប់ការគ្រប់គ្រងឆ្នាំ ២០០០ ដែលប្រកាសឱ្យប្រើ ដោយព្រះរាជក្រមលេខ នស/រកម/១២៩៩/១៥ ចុះថ្ងៃទី ២៥ ខែ ធ្នូ ឆ្នាំ ១៩៩៩ និង ត្រូវបានកែប្រែដោយច្បាប់ ស្តីពីវិសោធនកម្មមាត្រា ២៦ នៃច្បាប់ ស្តីអំពីប្រព័ន្ធហិរញ្ញវត្ថុ ដែលប្រកាសឱ្យប្រើ ដោយព្រះរាជក្រមលេខ នស/រកម/១២០២/០២០ ចុះថ្ងៃទី ៣០ ខែ ធ្នូ ឆ្នាំ ២០០២
- បានឃើញព្រះរាជក្រមលេខ ជស/រកម/០២៩៨/០៣ ចុះថ្ងៃទី ២៥ ខែ កុម្ភៈ ឆ្នាំ ១៩៩៨ ដែលប្រកាសឱ្យប្រើដោយច្បាប់ ស្តីពីរបបហិរញ្ញវត្ថុ និង ទ្រព្យសម្បត្តិខេត្ត ក្រុង

បានឃើញព្រះរាជក្រមលេខ នស/រកម/១២០២/០២១ ចុះថ្ងៃទី ៣០ ខែ ធ្នូ ឆ្នាំ ២០០២ ដែល ប្រកាសឱ្យប្រើច្បាប់ ស្តីពីហិរញ្ញវត្ថុ សំរាប់ការគ្រប់គ្រងឆ្នាំ ២០០៣

- តាមការចាំបាច់របស់រាជរដ្ឋាភិបាល

## សំរេច

**មាត្រា ១.-** អនុក្រឹត្យនេះ បង្កើតឡើងក្នុងគោលបំណង អនុញ្ញាតឱ្យអនុវត្តជាបណ្តោះអាសន្ន លើចំណាយប្រចាំខែ ក្នុងកំរិត មួយភាគដប់ពីរ នៃថវិកា ដែលបានអនុម័តឆ្នាំ ២០០៣ និង លើការប្រមូលចំណូលតាមលក្ខខណ្ឌ នៃច្បាប់ដែលបានអនុម័តកន្លងមក ក្នុងករណី សេចក្តីព្រាងច្បាប់ស្តីពីហិរញ្ញវត្ថុ សំរាប់ការគ្រប់គ្រងឆ្នាំ ២០០៤ មិនបានអនុម័តនៅមុនថ្ងៃទី ០១ ខែ មករា ឆ្នាំ ២០០៤ ។

**មាត្រា ២.-** ការប្រមូលចំណូលគ្រប់ប្រភេទ ត្រូវបានបន្ត និង អនុញ្ញាតឱ្យប្រមូល ក្នុងលក្ខខណ្ឌ និង តាមបែបបទ ដែលបានកំណត់ដោយច្បាប់ហិរញ្ញវត្ថុ ដែលបានចែងពីមុន និង ដោយនីតិកម្ម ព្រមទាំងបទបញ្ជា ដែលមានជាធរមាន ។

**មាត្រា ៣.-** ចំណាយចរន្តនៃថវិកាឆ្នាំ ២០០៤ ក្រៅពីបន្ទុកសេវាបំណុលសាធារណៈ នៅតែបន្តប្រតិបត្តិតាមថវិកាឆ្នាំ ២០០៣ ដែលបានកំណត់ មានចំនួនទឹកប្រាក់ ១.៧៣៧.០០០ លានរៀល ដោយគិតតាមវិធីមួយភាគដប់ពីរ ជាបណ្តោះអាសន្ន តាមខែនិមួយៗ រហូតដល់មានអន្តរាគមន៍ ពីថវិកាឆ្នាំ ២០០៤ ។

**មាត្រា ៤.-** ចំណាយជាមូលធននៃថវិកាឆ្នាំ ២០០៤ ក្រៅពីការរំលស់បំណុលសាធារណៈ នៅតែបន្តប្រតិបត្តិការ តាមគំរោងថវិកាឆ្នាំ ២០០៣ ក្នុងក្របខ័ណ្ឌនៃឥណទានទូទាត់ ដែលនៅសល់ទំនេរ ហើយបើសិនជាចាំបាច់ អាចចំណាយលើសពីនេះ ដោយមិនឱ្យការទូទាត់នោះ លើសពីកំរិតឥណទានភ្ជាប់សន្យា ដែលបានអនុម័ត (ចំណាយវិនិយោគក្នុងស្រុក : ឥណទានភ្ជាប់សន្យា - ឥណទានទូទាត់) ។

**មាត្រា ៥.-** ចំណាយទាំងឡាយ ដែលទាក់ទងទៅនឹងសេវា និង ការរំលស់បំណុលសាធារណៈ ត្រូវបានរ៉ាប់រងជាបន្តបន្ទាប់មិនឱ្យដាច់ តាមតារាងរំលស់ និង ការប្រាក់ ដែលបានចុះកិច្ចព្រមព្រៀងកន្លងមក ។

**មាត្រា ៦.-** ចំណូលចរន្តនៃថវិកាខេត្ត ក្រុង ឆ្នាំ ២០០៤ ត្រូវបានបន្ត និង អនុញ្ញាតឱ្យប្រមូល ក្នុងលក្ខខណ្ឌ និង តាមបែបបទ ដូចបានកំណត់នៅក្នុងច្បាប់ហិរញ្ញវត្ថុ ដែលបានចែងពីមុន និង ដោយនីតិកម្ម ព្រមទាំងបទបញ្ជា ដែលមានជាធរមាន ។ ចំណាយចរន្តនៃថវិកាខេត្ត ក្រុង ដែលបានកំណត់នៅក្នុងច្បាប់ស្តីពីហិរញ្ញវត្ថុ សំរាប់ការគ្រប់គ្រងឆ្នាំ ២០០៣ មានចំនួនទឹកប្រាក់ ៤៩.០០០ លានរៀល ត្រូវបានបន្ត

អនុវត្ត នៅក្នុងឆ្នាំ ២០០៤ ដោយគិតក្នុងកំរិត មួយភាគដប់ពីរ ជាបណ្ដោះអាសន្ន សំរាប់ខែនិមួយៗ រហូតដល់មានអន្តរាគមន៍ ពីថវិកាឆ្នាំ ២០០៤ ។

**មាត្រា ៧.-** ការបែងចែកឥណទានថវិកា នៅតាមក្រសួង ស្ថាប័ន និង ខេត្ត ក្រុង និមួយៗ ក៏ដូចជាការបែងចែកឥណទានថវិកាផ្ទៃក្នុង ជាជំពូក ប្រការ កថាខ័ណ្ឌ និង វាក្យខ័ណ្ឌ តាមខែនិមួយៗ ត្រូវធ្វើឡើងតាមប្រកាស របស់រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ ។

**មាត្រា ៨.-** រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ និង រដ្ឋមន្ត្រីគ្រប់ក្រសួង រដ្ឋលេខាធិការគ្រប់រដ្ឋលេខាធិការដ្ឋាន អភិបាលគ្រប់ខេត្ត ក្រុង និង ស្ថាប័ននានា ដែលមានការពាក់ព័ន្ធ ត្រូវទទួលបន្ទុកអនុវត្តអនុក្រឹត្យនេះ ចាប់ពីថ្ងៃចុះហត្ថលេខាតទៅ ។

រាជធានីភ្នំពេញ ថ្ងៃទី ២៨ ខែ ធ្នូ ឆ្នាំ ២០០៣

នាយករដ្ឋមន្ត្រី

**ហ៊ុន សែន**

<u>ចំលងជូន</u>

- ក្រសួងព្រះបរមរាជវាំង
- អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា
- អគ្គលេខាធិការដ្ឋានរដ្ឋសភា
- ខុទ្ទកាល័យសម្តេចនាយករដ្ឋមន្ត្រី
- ដូចមាត្រា ៨
- កាលប្បវត្តិ - ឯកសារ

**បានយកសេចក្តីជំរាបជូន**
**សម្តេចនាយករដ្ឋមន្ត្រី ដើម្បីសូមចុះហត្ថលេខា**

**គាត ឈន់**
**ទេសរដ្ឋមន្ត្រី**
**រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ**